ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងរដ្ឋប្បវេណីលេខៈ ០៦១
ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩
សាលក្រមលេខៈ ២៣ (ត)
ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២០

## តាមនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកណ្តាល

បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២០

**ចៅក្រម**

លោកស្រី [redacted] ចៅក្រមនៃសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្តាល

**ដើមចោទ:** ឈ្មោះ [redacted] វ៉ាន់ថា ភេទប្រុស កើតឆ្នាំ១៩៨២ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន [redacted] ។

លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ ។

**ចុងចម្លើយ:** ឈ្មោះ [redacted] ស្មើ ភេទស្រី ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន [redacted] ។

លោក [redacted] និងលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយ ។

## អង្គហេតុ និងចំណុចវិវាទ

I- ការទាមទាររបស់ដើមចោទ:

១. សុំឲ្យតុលាការចេញសាលក្រមលែងលះពីចុងចម្លើយឈ្មោះ [redacted] ស្មើ ។

២. សុំមានអំណាចមេបាលើកូនចំនួន០១នាក់មាន៖

- ឈ្មោះ [redacted] វណ្ណថៃ ភេទប្រុស កើតថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៩ ។

៣. សុំគ្រប់គ្រងសម្បត្តិដោយឡែកមាន៖

- តូបលក់ដូរ និងឥវ៉ាន់
- ម៉ាស៊ីនភ្លើង មេក្រូ និងធុងបាស់
- ម៉ូតូសង់កូរ៉េម៉ាស៊ីន ១០០CC មួយគ្រឿង

៤. សុំបែកចែកទ្រព្យសម្បត្តិរួមជាពីរចំណែកស្មើគ្នា មាន៖

- ខ្សែក [redacted] ឈុត បន្ទះខ្សែដៃ ខ្សែជើង ជញ្ជៀន និងក្រវិល សរុបតម្លៃប្រហែល ១៨០០$



Scanned with CamScanner

- ម៉ូតូZOOMER X-2017មួយគ្រឿង ដែលមានស្លាកលេខ កណ្ដាល1U-2798 តម្លៃ២១៣០$
- លុយដកពីធនាគារ ៣០០០$ ដើម្បីយកមករកស៊ី។ ខ្លួនបានយកប្រើប្រាស់ក្នុងការទិញឥវ៉ាន់អស់ ១៨០០$ ប៉ុណ្ណោះ សល់ ១២០០$
- ចុងចម្លើយបានលួចដកលុយធនាគារ នៅថ្ងៃទី១៧ ខែតុលា ចំនួន ៩៩៩០$(ប្រាំបួនពាន់ប្រាំបួនរយកៅសិប)ដុល្លាអាមេរិក ដែលមិនបានប្រាប់ខ្លួនជាប្ដី
- លុយដែលចុងចម្លើយបង់ផ្ដាច់ធនាគារ អស់ចំនួន ៩៤២០$ នៅសល់ចំនួន ៥៧០$
- នៅជំពាក់ធនាគារ១០០០$ ខ្លួនជាប្ដីត្រូវបង់ម្នាក់ឯង ក្នុងមួយខែចំនួន២៥$បង់បាន០៤ខែ
- ដីមួយកន្លែងបានទិញរួមគ្នាលើកទី១ មានទទឹង៨ម៉ែត្រ ,បណ្ដោយ២៥ម៉ែត្រ មានទំហំ២០០ ម៉ែត្រការ៉េ ដែលមានទីតាំងដីស្ថិតនៅភូមិពោធិបាន ឃុំពោធិបាន ស្រុកកោះធំ ខេត្តកណ្ដាល ដែលមានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ ជាងឌី ខាងត្បូងទល់នឹងឈ្មោះ សារឿន ខាងកើតជាប់ដីកេរ្ដិ៍ ដែលឪក្មេក និងម៉ែក្មេកចែកឲ្យ ខាងលិចទល់នឹងឈ្មោះ ពូផន និងមីងទូច ។
- ដីដែលបានទិញរួមគ្នាលើកទី២ បានទិញពីឈ្មោះ ពូផន និងប្រពន្ធឈ្មោះ មីង ទូច ដែលមានទទឹង៨ម៉ែត្រ និងបណ្ដោយ២៩ម៉ែត្រ មានទំហំ២៣២ម៉ែត្រការ៉េ ដែលមានទីតាំងដីស្ថិតនៅភូមិពោធិបាន ឃុំពោធិបាន ស្រុកកោះធំ ខេត្តកណ្ដាល ដែលមានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ ឌី ខាងត្បូងទល់នឹងឈ្មោះ សារឿន ខាងកើតទល់នឹងដីខ្លួនបានទិញខាងលើលើកទី១ ខាងលិចទល់នឹងផ្លូវបេតុង ។
- ទ្រព្យសម្បត្តិដែលបានឲ្យម៉ែក្មេកខ្ចី មានថ្លៃជាងធ្វើផ្ទះចំនួន ៨០០$,ម៉ូតូ HONDA DREAM ស៊េរី២០១៤ ដែលមានស្លាកលេខ ភ្នំពេញ 1C-8690 បានទិញក្នុងតម្លៃ ១៧០០$ តូបធ្វើអស់ចំនួន ៩០០$ ,ខ្សែដៃមួយតម្លៃ ៨០០$ សរុប៤២០០$ (បួនពាន់ពីររយ)ដុល្លា ។

II- ការអះអាងរបស់គូភាគី:

- ដើមចោទបានធ្វើសេចក្ដីថ្លែងការណ៍ថា: ខ្លួននៅតែប្ដឹងសុំលែងលះពីចុងចម្លើយ ដូចក្នុងពាក្យបណ្ដឹងដដែល។ ខ្លួនរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយឈ្មោះ [redacted] ស្មើ កាលពីខែឧសភា ឆ្នាំ២០១៨ មានតែប័ណ្ណប្រកាសរៀបអាពាហ៍ពិពាហ៍ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៨ ។ ក្នុងអំឡុងពេលរួមរស់ជាមួយគ្នាមានកូនប្រុសម្នាក់ឈ្មោះ [redacted] វណ្ណថៃ កើតថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៩។ ខ្លួននិងចុងចម្លើយចេះតែមានបញ្ហារកាំរកូសឈ្លោះប្រកែកគ្នារស់នៅមិនចុះសំរុងនិងគ្នាធ្វើឲ្យខ្លួនអស់មនោសញ្ចេតនារួមរស់ជាប្ដីប្រពន្ធតទៅទៀត ។ ខ្លួនសុខចិត្តប្រគល់កូនឲ្យទៅប្រពន្ធនិងបង់ប្រាក់ចិញ្ចឹមកូនរៀងរាល់ខែក្នុងមួយខែចំនួន៥០ដុល្លាអាមេរិក ខ្លួនមិនមានលទ្ធភាពបង់ប្រាក់ចិញ្ចឹមកូនផ្ដាច់ ចំនួន ៤៨០០ ដុល្លាអាមេរិក ឲ្យទៅចុងចម្លើយទេ។ ទ្រព្យសម្បត្តិរួមមាន ម៉ូតូចំនួន០២គ្រឿង ម៉ាកសង់ស៊េរីឆ្នាំ២០១៤ ចំនួន០១គ្រឿង និងម៉ូតូម៉ាក ZOOMER - X ស៊េរីឆ្នាំ២០១៧ ចំនួន០១គ្រឿង សព្វថ្ងៃនៅចុងចម្លើយគ្រប់គ្រង។ ខ្លួនសុំម៉ូតូ ម៉ាកសង់ស៊េរីឆ្នាំ២០១៤



Scanned with CamScanner

ចំនួន០១គ្រឿង ឯម៉ូតូ ម៉ាក ZOOMER-X ស៊េរីឆ្នាំ២០១៧ ចំនួន០១គ្រឿង ទុកឲ្យចុងចម្លើយ និងដីចំនួន ០២កន្លែង គឺមួយកន្លែងមានទំហំទទឹង៨ម៉ែត្រ ,បណ្តោយ២៥ម៉ែត្រ មានទំហំ ២០០ម៉ែត្រការ៉េ ដែលមានទីតាំងដីស្ថិតនៅភូមិពោធិបាន ឃុំពោធិបាន ស្រុកកោះធំ ខេត្តកណ្តាល និងមួយកន្លែងទៀត មានទទឹង៨ម៉ែត្រ និងបណ្តោយ២៩ម៉ែត្រ មានទំហំ ២៣២ម៉ែត្រការ៉េ ដែលមានទីតាំងដី ស្ថិតនៅភូមិពោធិបាន ឃុំពោធិបាន ស្រុកកោះធំ ខេត្តកណ្តាល អត់មានឯកសារ សុំលក់យកប្រាក់ចែកគ្នា។ ឯទ្រព្យសម្បត្តិផ្សេងពីនេះខ្លួនអត់លើកមកនិយាយទេ។ ប្រាក់ដែលខ្លួនផ្ញើមកឲ្យទិញម៉ូតូ ស្លាកលេខ ភ្នំពេញ 1C-8690 មិនមែនផ្ញើមកសងម្តាយក្មេកដូចគាត់ថាទេ បានជាដាក់ឈ្មោះប្រពន្ធម្នាក់ឯងដោយសារខ្លួននៅប្រទេសកូរ៉េ ។ ពេលខ្លួនទៅប្រទេសកូរ៉េម្តាយក្មេកខ្លួន មិនបានផ្គុំងផ្តើមចេញប្រាក់ឲ្យខ្លួនទេ គឺយកប្រាក់ដែលយកដី ៨ម៉ែត្រ X ២៥ម៉ែត្រ ដាក់ធនា គារយកប្រាក់ប្រហែល៣០០០ដុល្លាអាមេរិក ដើម្បីទៅធ្វើការនៅប្រទេសកូរ៉េ ។

- ចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍ថា: ខ្លួនឯកភាពលែងលះពីចុងចម្លើយ និងសុំគ្រប់គ្រងកូនប្រុសម្នាក់ឈ្មោះ [redacted] វណ្ណថៃ កើតថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៩ និងសុំឲ្យដើមចោទបង់ប្រាក់ចិញ្ចឹមកូនផ្តាច់ចំនួន៤៨០០ដុល្លាអាមេរិក។ ដីចំនួន០២កន្លែង សុំចែកជាពីរចំណែក។ ម៉ូតូជាទ្រព្យសម្បត្តិរួមមានតែមួយគ្រឿងគឺ ម៉ាក ZOOMER-X ស៊េរីឆ្នាំ២០១៧ ស្លាកលេខ កណ្តាល ២៧៩៨ សព្វថ្ងៃខ្លួនលក់ហើយយកប្រាក់ឲ្យកូនចាយ ។ ឯម៉ូតូសង់ចំនួនមួយគ្រឿង មិនមែនទ្រព្យសម្បត្តិរួមទេ ជាម៉ូតូរបស់ម្តាយខ្លួនសព្វថ្ងៃនៅម្តាយខ្លួនគ្រប់គ្រង ឯប្រាក់ដែលដើមចោទផ្ញើមកមិនមែនដើម្បីយកទិញម៉ូតូទេ គឺដើម្បីសងម្តាយខ្លួនហើយម៉ូតូនេះខ្លួនជាអ្នកទៅទិញឲ្យម្តាយខ្លួន។ ឯទ្រព្យសម្បត្តិផ្សេងពីនេះខ្លួនអត់លើកមកនិយាយទេ។

– ឈ្មោះ [redacted] ម៉ាប់ ជាសាក្សីសំអាងចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍ថា: ខ្លួនត្រូវជាម្តាយបង្កើតរបស់ឈ្មោះ [redacted] ស្មើ ។ ម៉ូតូ ស្លាកលេខ 1C-8690 ជាម៉ូតូរបស់ខ្លួនៗឲ្យប្រាក់ទៅកូនឈ្មោះ [redacted] ស្មើទៅទិញ តែដាក់ឈ្មោះកូនឈ្មោះ [redacted] ស្មើ ហើយប្រាក់ដែលយកទៅទិញនោះគឺជាប្រាក់ដែលកូនប្រសារឈ្មោះ [redacted] វ៉ាន់ថា ផ្ញើប្រាក់សងខ្លួនពីប្រទេសកូរ៉េមក មិនមែនផ្ញើប្រាក់ដើម្បីទិញម៉ូតូទេ ព្រោះពេលកូនប្រសារទៅប្រទេសកូរ៉េខ្លួនអ្នកផ្គុំងផ្តើមចេញប្រាក់ឲ្យគាត់ហើយពេលគាត់ធ្វើការនៅប្រទេសកូរ៉េបានផ្ញើប្រាក់សងខ្លួនវិញ។ ម៉ូតូតម្លៃ ១៧០០ ដុល្លាសព្វថ្ងៃនៅខ្លួនប្រើប្រាស់ទិញកាលឆ្នាំ២០១៤ ។

– មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា: ឯកភាពតាមការព្រមព្រៀងរបស់កូនក្តីខ្លួន សុំតុលាការសម្រេចតាមច្បាប់ ។

– មេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍ថា: ខ្លួនរក្សាសេចក្តីថ្លែងការណ៍ពីមុនមក កូនក្តីខ្លួនសុំឲ្យដើមចោទបង់អាហារកិច្ចផ្តាច់ ក្រៅពីនេះអត់មានអ្វីទៀតទេ សូមតុលាការសម្រេចតាមច្បាប់ ។

## III- ចំណុចវិវាទ:

- ដើមចោទ និងចុងចម្លើយមិនឯកភាពគ្នាលើសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ។
- ដើមចោទអះអាងថាម៉ូតូ ម៉ាកសង់ស៊េរីឆ្នាំ២០១៤ ស្លាកលេខ ភ្នំពេញ 1C-8690 ចំនួន០១គ្រឿង ជាទ្រព្យសម្បត្តិរួម ឯចុងចម្លើយអះអាងថាមិនមែនមិនជាទ្រព្យសម្បត្តិរួម ។



Scanned with CamScanner

## សំអាងហេតុ

- ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាតែពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នា បញ្ជាក់ថាដើមចោទនិងចុងចម្លើយរស់នៅជាមួយគ្នាបែបអនីតិសង្វាស។

- ដើមចោទឈ្មោះ [redacted] វ៉ាន់ថា ប្តឹងសុំលែងលះពីចុងចម្លើយឈ្មោះ [redacted] រស្មី ប៉ុន្តែដោយសារដើមចោទនិងចុងចម្លើយពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នា គប្បីច្រានចោលការទាមទារសុំលែងលះហើយសម្រេចឲ្យដើមចោទនិងចុងចម្លើយបានផ្តាច់អនីតិសង្វាសវិញ។

- ដើមចោទសុខចិត្តប្រគល់កូនប្រុសម្នាក់ឈ្មោះ [redacted] វណ្ណថៃ ឲ្យទៅចុងចម្លើយគ្រប់គ្រងថែរក្សា ឯចុងចម្លើយក៏បានឯកភាពដែរ គប្បីសម្រេចតាមការព្រមព្រៀងរបស់គូភាគី ។

- ដើមចោទសុំផ្តល់ប្រាក់ចិញ្ចឹមកូនក្នុងមួយខែចំនួន ៥០ដុល្លាអាមេរិក ឯចុងចម្លើយមិនឯកភាព ដោយសុំប្រាក់ចិញ្ចឹមកូនផ្តាច់ចំនួន ៤៨០០ ដុល្លាអាមេរិក គប្បីសម្រេចតាមសភាពជាក់ស្តែង ។

- ដើមចោទអះអាងថា ម៉ូតូម៉ាកសង់ស៊េរីឆ្នាំ២០១៤ ស្លាកលេខ ភ្នំពេញ 1C-8690 ចំនួន០១គ្រឿង ជាទ្រព្យសម្បត្តិរួម ឯចុងចម្លើយអះអាងថា មិនមែនជាទ្រព្យសម្បត្តិរួមជាម៉ូតូរបស់ម្តាយខ្លួន ។

- ឈ្មោះ [redacted] ម៉ាប់ ជាម្តាយបង្កើតរបស់ចុងចម្លើយឈ្មោះ [redacted] រស្មី បានអះអាងថា ម៉ូតូ ស្លាកលេខ 1C-8690 ជាម៉ូតូរបស់ខ្លួនៗឲ្យប្រាក់ទៅកូនឈ្មោះ [redacted] រស្មី ទៅទិញ តែដាក់ឈ្មោះកូនឈ្មោះ [redacted] រស្មី ហើយប្រាក់ដែលយកទៅទិញនោះគឺជាប្រាក់ដែលកូនប្រសារឈ្មោះ [redacted] វ៉ាន់ថា ផ្ញើប្រាក់សងខ្លួនពីប្រទេសកូរ៉េមក មិនមែនផ្ញើប្រាក់ដើម្បីទិញម៉ូតូទេ ព្រោះពេលកូនប្រសារទៅប្រទេសកូរ៉េខ្លួនអ្នកផ្ទុងផ្តើមចេញប្រាក់ឲ្យគាត់ហើយពេលគាត់ធ្វើការនៅប្រទេសកូរ៉េបានផ្ញើប្រាក់សងខ្លួនវិញ។ ប៉ុន្តែដើមចោទឈ្មោះ [redacted] វ៉ាន់ថា បានអះអាងថា ប្រាក់ដែលខ្លួនផ្ញើមកឲ្យទិញម៉ូតូ ស្លាកលេខ ភ្នំពេញ 1C-8690 មិនមែនផ្ញើមកសងម្តាយក្មេកដូចគាត់ថាទេ បានជាដាក់ឈ្មោះប្រពន្ធម្នាក់ឯងដោយសារខ្លួននៅប្រទេសកូរ៉េ។ ពេលខ្លួនទៅប្រទេសកូរ៉េម្តាយក្មេកខ្លួន មិនបានផ្ទុងផ្តើមចេញប្រាក់ឲ្យខ្លួនទេ គឺយកប្រាក់ដែលយកដី ៨ម៉ែត្រ X ២៥ម៉ែត្រ ដាក់ធនាគារយកប្រាក់ប្រហែល៣០០០ដុល្លាអាមេរិក ដើម្បីទៅធ្វើការនៅប្រទេសកូរ៉េ ។ ដូច្នេះបញ្ជាក់ថា ម៉ូតូម៉ាកសង់ស៊េរីឆ្នាំ២០១៤ ស្លាកលេខ ភ្នំពេញ 1C-8690 ចំនួន០១គ្រឿង ជាទ្រព្យសម្បត្តិរួម ។

- ទ្រព្យសម្បត្តិរួមមាន:

  - ដីចំនួន០២កន្លែង គឺមួយកន្លែងមានទំហំទទឹង៨ម៉ែត្រ ,បណ្តោយ២៥ម៉ែត្រ មានទំហំ ២០០ម៉ែត្រការ៉េ ដែលមានទីតាំងដីស្ថិតនៅភូមិពោធិបាន ឃុំពោធិបាន ស្រុកកោះធំ ខេត្តកណ្តាល និងមួយកន្លែងទៀត មានទទឹង៨ម៉ែត្រ និងបណ្តោយ២៩ម៉ែត្រ មានទំហំ ២៣២ម៉ែត្រការ៉េ ដែលមានទីតាំងដី ស្ថិតនៅភូមិពោធិបាន ឃុំពោធិបាន ស្រុកកោះធំ ខេត្តកណ្តាល អត់មានឯកសារ គប្បីបែងចែកជាពីរចំណែកស្មើគ្នាតាមការព្រមព្រៀងរបស់គូភាគី ។

  - ម៉ូតូចំនួន០២គ្រឿង ម៉ាកសង់ស៊េរីឆ្នាំ២០១៤ ស្លាកលេខ ភ្នំពេញ 1C-8690 ចំនួន០១គ្រឿង និងម៉ូតូម៉ាកZOOMER-X ស៊េរីឆ្នាំ២០១៧ ស្លាកលេខ កណ្តាល 1U-2798 ចំនួន០១គ្រឿង គប្បីបែង



Scanned with CamScanner

ចែកជាពីរចំណែកស្មើគ្នា ។

- តាមបញ្ញត្តិមាត្រា ៩៨០,១០៣៧ និងមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី ។

**សេចក្តីសម្រេចបញ្ចប់**

១- ច្រានចោលការទាមទារសុំសាលក្រមលែងលះពីចុងចម្លើយរបស់ដើមចោទឈ្មោះ [redacted] វ៉ាន់ថា។

២- ក. ឲ្យដើមចោទឈ្មោះ [redacted] វ៉ាន់ថា និងចុងចម្លើយឈ្មោះ [redacted] វស្មី បានផ្តាច់អនីតិសង្វាស តាមការព្រមព្រៀងរបស់គូភាគី ។

ខ. ប្រគល់អំណាចមេបាឲ្យទៅចុងចម្លើយឈ្មោះ [redacted] វស្មី ជាម្តាយដើម្បីគ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សាកូនប្រុសម្នាក់ឈ្មោះ [redacted] វណ្ណថៃ កើតថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៩ តាមការព្រមព្រៀងរបស់គូភាគី ។ ឲ្យដើមចោទឈ្មោះ [redacted] វ៉ាន់ថា ជាឪពុកដែលពុំមានអំណាចមេបាមានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន ជារៀងរាល់ខែនៅសប្តាហ៍ទីមួយ ប៉ុន្តែចុងចម្លើយឈ្មោះ [redacted] វស្មី ត្រូវបង្កលក្ខណៈងាយស្រួលឲ្យដើមចោទឈ្មោះ [redacted] វ៉ាន់ថា ជាឪពុកដែលពុំមានអំណាចមេបាចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន ។

គ. ឲ្យដើមចោទឈ្មោះ [redacted] វ៉ាន់ថា ទទួលបន្ទុកបង់សោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនក្នុងមួយខែ ចំនួន ៥០ដុល្លាអាមេរិក ហូតដល់កូនប្រុសឈ្មោះ [redacted] វណ្ណថៃ គ្រប់អាយុនីតិភាព។

ឃ. ទ្រព្យសម្បត្តិរួមមាន:

- ម៉ូតូចំនួន០២គ្រឿង ម៉ាកសង់ស៊េរីឆ្នាំ២០១៤ ស្លាកលេខ ភ្នំពេញ 1C-8690 ចំនួន០១គ្រឿង និងម៉ូតូម៉ាក ZOOMER-X ស៊េរីឆ្នាំ២០១៧ ស្លាកលេខ កណ្តាល 1U-2798 ចំនួន០១គ្រឿង ត្រូវបែងចែកឲ្យដើមចោទ និងចុងចម្លើយជាពីរចំណែកស្មើគ្នា។

- ដីចំនួន០២កន្លែង គឺមួយកន្លែងមានទំហំទទឹង៨ម៉ែត្រ ,បណ្តោយ២៥ម៉ែត្រ មានទំហំ ២០០ម៉ែត្រការ៉េ ដែលមានទីតាំងដីស្ថិតនៅភូមិពោធិបាន ឃុំពោធិបាន ស្រុកកោះធំ ខេត្តកណ្តាល និងមួយកន្លែងទៀត មានទទឹង៨ម៉ែត្រ និងបណ្តោយ២៩ម៉ែត្រ មានទំហំ ២៣២ម៉ែត្រការ៉េ ដែលមានទីតាំងដី ស្ថិតនៅភូមិពោធិបាន ឃុំពោធិបាន ស្រុកកោះធំ ខេត្តកណ្តាល អត់មានឯកសារ ត្រូវបែងចែកឲ្យដើមចោទ និងចុងចម្លើយជាពីរចំណែកស្មើគ្នាតាមការព្រមព្រៀងរបស់គូភាគី ។

២- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

៣- សាលក្រមនេះចំពោះមុខភាគីដើមចោទ និងភាគីចុងចម្លើយ ។

" ទុកសិទ្ធិឲ្យដើមចោទ និងចុងចម្លើយ ប្តឹងឧទ្ធរណ៍រយៈពេល០១ខែ គិតចាប់ពីថ្ងៃបានទទួលអនុសារសាលក្រមនេះ "

**ចៅក្រម**

ហត្ថលេខា និងត្រា: [redacted]



Scanned with CamScanner

“បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម”
ថ្ងៃចន្ទ ៦កើត ខែកទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
កណ្តាល , ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០

**បានឃើញ**
**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]